ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិកោះស្នែង
# សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦ - ២០១៨)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | កោះស្នែង |
| ភូមិ | ៖ | កោះស្នែង |
| ឃុំ | ៖ | កោះស្នែង |
| ស្រុក | ៖ | ថាឡាបរិវ៉ាត់ |
| ខេត្ត | ៖ | ស្ទឹងត្រែង |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិកោះស្នែង
# សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦ - ២០១៨)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | កោះស្នែង |
| ភូមិ | ៖ | កោះស្នែង |
| ឃុំ | ៖ | កោះស្នែង |
| ស្រុក | ៖ | ថាឡាបរិវ៉ាត់ |
| ខេត្ត | ៖ | ស្ទឹងត្រែង |

**២០១៥**

## មាតិកា

**១.ស្ថានភាពទូទៅ**..........................................................................................................៤
**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម**..........................................................................................៥
ក.ប្រជាពលរដ្ឋ .................................................................................................................៥
ខ. មុខរបរ .......................................................................................................................៥
**៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**..............................៦
ក. ទីតាំង ..........................................................................................................................៦
ខ. ដែននេសាទ...................................................................................................................៧
ខ.១.អូរ ...........................................................................................................................៧
ខ.២.កោះ ..........................................................................................................................៧
ខ.៣.អន្លង់.........................................................................................................................៨
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស.................................................................៨
ឃ. ធនធានជលផល ..............................................................................................................៨
១.ប្រភេទត្រី .......................................................................................................................៨
២.ប្រភេទវារីសត្វ ..................................................................................................................៩
៣.ប្រភេទបក្សី .....................................................................................................................៩
៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ .............................................................................៩
**៤.ការធ្វើនេសាទ** ...............................................................................................................៩
ក.អ្នកនេសាទ.......................................................................................................................៩
ខ.ឧបករណ៍នេសាទ ..............................................................................................................៩
គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..........................................................................១១
**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ..........................................................................១១
ក.ទស្សនៈវិស័យ ...............................................................................................................១១
ខ.គោលបំណង ...................................................................................................................១១
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍..........................................................................១២
គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ...............................................................................១២

គ.២. ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ ......................................................................១៣
គ.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ......................................................................១៣
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ......................................................................................១៤
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម .....................................................................................១៥
គ.៦. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ......................................................................១៥
គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ .....................................................................................១៧
គ.៨. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ............................................................១៩
គ.៩. ផែនការផ្សព្វផ្សាយបណ្តុះបណ្តាល និង បង្កើនការយល់ដឹង.............................................២០
គ.១០. ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍន៍សហគមន៍..........................................................២១
ឃ. យុទ្ធសាស្ត្រ.............................................................................................................២២
**៦.ឧបសម្ពន្ធ**
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៦-២០១៨.............២៣
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៦-២០១៨.............................................................៣៥

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ១- ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិកោះស្នែង ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ២០០៦ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅក្នុងភូមិកោះស្នែង ឃុំកោះស្នែង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន ១៤៤គ្រួសារ ស្មើនឹង ៥៩១នាក់ (ស្រីចំនួន២៥៩នាក់) និងមានគណៈកម្មការចំនួន ០៧ នាក់(ស្រីចំនួន ០១ នាក់)។ សហគមន៍នេសាទភូមិកោះស្នែង ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

នៅពេលដែលសហគមន៍នេសាទត្រូវបានបង្កើតនៅឆ្នាំ២០០០ សកម្មភាពដែលកើតក្នុងតំបន់ដូចជា: ការកាប់បំផ្លាញព្រៃលិច ការប្រើឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់គ្រឿងផ្ទុះ ឧបករណ៍ឆក់ មងក្រឡាធំៗ កាប់ព្រៃលិចទឹក និងសារជាតិពុល) ជាដើម។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទក៏អនុវត្តសកម្មភាពសំខាន់ៗរបស់ខ្លួនដូចជា: រៀបចំភារៈកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ រៀបចំក្រុមល្បាត រៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈនិងបទបញ្ជា ផ្ទៃក្នុងចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទ ចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា ចុះល្បាតជាប្រចាំដោយសហការជាមួយសមត្ថកិច្ចជលផល និងអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងនេសាទសហគមន៍។

នៅឆ្នាំ ២០០៦ រហូតដល់បច្ចុប្បន្ន សហគមន៍នេសាទបានធ្វើការអះអាងពីការជោគជ័យរបស់ខ្លួន ក្នុងការលុបបំបាត់ការកាប់ព្រៃលិចទឹកបាន៨៩% និងបានកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានាដើម្បីឲ្យផលនេសាទមានការកើនឡើង។ ការរីកចំរើនដោយសារតែអ្នកភូមិមានការយល់ដឹងការចូលរួមពីសហគមន៍ និងតម្រូវការលើធនធានធម្មជាតិ ជាពិសេសធនធានជលផល។ សហគមន៍នេសាទមានការទំនាក់ទំនងកិច្ចសហការណ៍ល្អជាមួយអាជ្ញាធរមូលដ្ឋាន អាជ្ញាធរដែនដី ស្ថាប័នជំនាញជលផលនិងមន្ទីរបរិស្ថានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល។

## ២-អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

ក.ប្រជាពលរដ្ឋ

សហគមន៍នេសាទភូមិកោះស្នែងមានចំនួនប្រជាពលរដ្ឋសរុប ២២០ គ្រួសារ ស្មើនឹង ១.១៧៤ នាក់ (ស្ត្រី៥៦១នាក់) (ទិន្នន័យឃុំឆ្នាំ ២០១៤) នៅក្នុងនោះមានជនជាតិខ្មែរចំនួន ១០០%។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៧ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ០៥ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ០៩នាក់ (ស្រី ០៧ នាក់)
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ ២៦ នាក់(ស្រី ០៧ នាក់)
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៦ នាក់(ស្រី ១១ នាក់)
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៩ នាក់ (ស្រី ០៧ នាក់)

ប្រជាពលរដ្ឋក្នុងសហគមន៍កោះស្នែងជាអ្នកកាន់សាសនាព្រះពុទ្ធមាន ១០០%។

ក្នុងចំណោមសមាជិកគ្រួសារទាំងអស់នៃភូមិកោះស្នែង អស់អ្នកមិនចេះអក្សរមានចំនួន ២៣១ នាក់ (ស្រី ១២៩ នាក់) កំរិតថ្នាក់បឋមសិក្សាចំនួនសរុប ១៨៩ នាក់ (ស្រី ៨៥ នាក់) កំរិតអនុវិទ្យាល័យចំនួនសរុប ៦៥ នាក់ (ស្រី ៣៩ នាក់) កំរិតវិទ្យាល័យចំនួនសរុប ៦ នាក់ (ស្រី ០៦ នាក់) និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ០ នាក់ (ស្រី ០ នាក់)។

ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន:

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ២២០ គ្រួសារ ស្មើនឹង១០០%
- ធ្វើស្រែចំនួន ២១៧ គ្រួសារ ដែលមានទំហំដីសរុបចំនួន ២០០ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន ២០ គ្រួសារ (សួនច្បារជាលក្ខណៈគ្រួសារដែលមាទំហំ ៣ x ៤ ម៉ែត្រ )
- ជាងផ្ទះចំនួន ១០ គ្រួសារ
- ធ្វើសិប្បកម្មគ្រឿងសង្ហារឹម(ធ្វើទ្វា បង្អួច )ចំនួន ០៧ គ្រួសារ
- លក់ដូរ១០ គ្រួសារ
- ធ្វើចំការចំនួន២១០ គ្រួសារដែលមានទំហំដីចំនួនសរុប ៥៩ហិកតា (ដាំដំណាំលក្ខណៈយូរអង្វែចំនួន១០គ្រួសារ ដូចជាស្វាយចន្ទី ស្វាយ ក្រូចពោធិសាត់(៩ហិចតា ) និង

២០០គ្រួសារដាំដំណាំចំរុះមានដូចជា ពោត សណ្តែក ល្ង ស្រូវ ដំឡូងដែលមាន ទំហំដីចាប់ពី ១-២ ហិចតា

- ប្រមូលទិញផលនេសាទ ០២ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១០០% នៃ ២២០ គ្រួសារក្នុងភូមិ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប ២២០ គ្រួសារ ផ្អក ប្រហុក ត្រីប្រៃ ជាដើម។ ក្នុងមួយគ្រួសារអាចផលិតបានចំនួនពី១០គីឡូក្រាម ទៅ១០០គីឡូក្រាមក្នុង ១គ្រួសារ
- ជាងកាត់ដេរ ០៧ នាក់
- ជាងជួសជុលម៉ូតូ និង កង់ចំនួន ០២ នាក់
- ជាងជួសជុលម៉ាស៊ីនទូកចំនួន ០២ នាក់
- ជាងធ្វើទូកចំនួន ០៨ នាក់
- ជាងធ្វើល្ងពាង ០២ នាក់
- ស៊ីឈ្នួលគេ (កម្មកររោងចក្រកាត់ដេ)ចំនួន ០៦នាក់
- ពេទ្យសត្វ ០២ នាក់
- ចំណាកស្រុកប្រទេសថៃ ៣៣ នាក់ ស្រី០៩នាក់ និងភ្នំពេញ ១១ នាក់ (ស្រី០៨ នាក់)។

**៣- កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ**

ក.ទីតាំង

កន្លែងនេសាទសហគមន៍ភូមិកោះស្នែង ជាដែននេសាទសាធារណៈរបស់រដ្ឋ។កន្លែងនេសាទ សហគមន៍ភូមិកោះស្នែងមានទំហំ ២.៤៨០ ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុង កិច្ចព្រមព្រៀង។

<u>មានព្រំប្រទល់</u> ៖

- ខាងជើងទល់នឹង អូរឈើទាលជាប់ដែននេសាទភូមិកោះកី ឃុំកោះស្នែង
- ខាងត្បូងទល់នឹង កន្ទុយកោះហាន
- ខាងកើតទល់នឹង អូរសំរោងសង្កាត់សាមគ្គី
- ខាងលិចទល់នឹង អូរឃ្លួយលំភូមិកោះស្រឡៅ ឃុំកោះស្នែង

ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិកោះស្នែង មានវិសាលភាពនៅក្នុងទន្លេមេគង្គដែលក្នុងនោះរួមមាន: អូរចំនួន ០៩អូរ កោះចំនួន ០៩ កោះ និងអន្លង់ចំនួន ០៦ អន្លង់។

ខ.១ អូរ

| ឈ្មោះអូរ | ប្រវែង (ម) | រដូវធ្វើនេសាទ |
|---|---|---|
| អូរឈើទាល | ១.០០០ | ខែ ០៨ - ខែ ១១ |
| អូរកំបោរ | ១.០០០ | ខែ ០៨- ខែ ១០ |
| អូរក្របៅធំ | ១.០០០ | ខែ ០៨ - ខែ ១១ |
| អូរក្របៅតូច | ២០០ | ខែ ០៨ - ខែ ១០ |
| អូរសំរោង | ៥០០ | ខែ ០៨ - ខែ ១១ |
| អូរព្រីង | ១.០០០ | ខែ ០៨ - ខែ ១១ |
| អូរក្បាលជូរ | ៥០០ | ខែ ០៨ - ខែ ១១ |
| អូរកងកែង | ១.០០០ | ខែ ០៨ - ខែ ១១ |
| អូរខ្ចូយលំ | ៥០០ | ខែ ០៨ - ខែ ១១ |

ខ.២ កោះ

| ឈ្មោះកោះ | ប្រវែង | | ទំហំសរុប (ហិកតា) |
|---|---|---|---|
| | ទទឹង(ម៉ែត្រ) | បណ្តោយ (ម៉ែត្រ) | |
| កោះហាន | ១.៥០០ | ៤.៥០០ | ៦៧៥ |
| កោះស្នែង | ១.៥០០ | ៤.០០០ | ៦០០ |
| កោះអំបិល | ៤០ | ១៥០ | ០.៦០ |
| កោះសំរោងធំ | ៥០ | ២៥០ | ១.២៥ |
| កោះសំរោងតូច | ២០ | ១០០ | ០.២០ |
| កោះតាលូន | ៥០ | ២០០ | ១.០០ |
| កោះកណ្តុរ | ១៥០ | ៣០០ | ៤.២៥ |
| កោះសំបួរ | ១០០ | ២៥០ | ២.៥០ |

| | | | |
|---|---|---|---|
| កោះទន្លេមួយ | ២០០០ | ៦០០០ | ១២០០ |

ខ.៣ អន្លង់

| ឈ្មោះអន្លង់ | ប្រវែង | | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|---|
| | ទទឹង (ម៉ែត្រ) | បណ្តោយ (ម៉ែត្រ) | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់តាលី | ១០០ | ៣០០ | ៣០.០០០ | ៣៣ | ២៣ |
| អន្លង់អំពិលឬ វ៉ើនខាម | ៥០ | ១០០ | ៥.០០០ | ២០ | ១០ |
| អន្លង់តាថាវ | ១៥០ | ៣០០ | ៤៥.០០០ | ៣៥ | ២៥ |
| អន្លង់ថ្មដំរី | ១៥០ | ២០០ | ៣០.០០០ | ៣១ | ២១ |
| អន្លង់កោះកណ្តុរ | ៥០ | ២០០ | ១០.០០០ | ៣០ | ២០ |
| អន្លង់កោះសំបួរ | ១០០ | ២៥០ | ២៥.០០០ | ១៩ | ៩ |

កន្លែងនេសាទសហគមន៍ភូមិកោះស្នែងព្រៃលិចទឹកមានទំហំសរុប ៨០ ហិកតា ក្នុងនោះមានប្រភេទព្រៃដើមរំដែងទំហំ ៣០ ហិកតា និងព្រៃលិចទឹកចំរុះទំហំ ៥០ ហិកតានៅក្នុងកន្លែងនេសាទសហគមន៍ភូមិកោះស្នែង។

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ៖

សហគមន៍នេសាទភូមិកោះស្នែងមានអន្លង់អភិរក្សចំនួន ០១ គឺអន្លង់តាថាវ ដូច្នេះសហគមន៍ឯកភាពគ្នាមិនបង្កើតកន្លែងអភិរក្សទៀតទេ។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់តាថាវ | ១៥០ x ៣០០ | ៤៥,០០០ | ៣៥ | ២៥ |

ឃ.ធនធានជលផល

១.ប្រភេទត្រី៖ ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ចង្វា កំភ្លាញ ឆ្លូញ ខ្មាន់ឆ្កិន ច្រកែង កន្ត្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ច្រូក កាហែ ត្រីលិញ ត្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឫស្សី ត្រីខ្ជឹង ត្រីខ្យា ត្រីកេះ ឆ្កោក ត្រីកែ ត្រីត្រសក់ ត្រីគល់រាំង ត្រីអណ្តែង

ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្មា ត្រីក្របី ត្រីកន្រ្តងប្រេង ត្រីឬសចេក ត្រីក្អុក ត្រីគ្រុំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអន្លុង ត្រីអាចម៍កុក។

២.ប្រភេទវារីសត្វ៖ ក្ដាម ខ្យង ខ្ចៅ គ្រំ លៀស អណ្ដើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីង គីង្គក់។

៣.ប្រភេទបក្សី៖ កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ ខ្លាត្រី ក្អែកទឹក ក្អែកគោក។

៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក៖ ដើមត្រែង ដើមអញ្ចេង ដើមរំចេក ដើមអណ្ដែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមថ្នាទឹក ដើមក្ដុល ដើមជ្រៃ ដើមព្រីង ដើមញ ដើមព្រុះទឹក ដើមទន្លា ដើមក្របៅ ដើមចេកទុំ ដើមពោធិ ដើមបន្លាឃ្លេ។

**៤-ការធ្វើនេសាទ**

ក.អ្នកនេសាទ

១-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៨៤គ្រួសារចំនួន ៤៩១នាក់(ស្រី២៥៩ នាក់)។

២-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៧៦គ្រួសារ

៣-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៣០គ្រួសារ

ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ

| ឧបករណ៍នេសាទ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ម៉ែត្រ | ១៨៤គ្រួសារ x ១០០ម =១៨.៤០០ម | ក្រឡា ២.៥០-១២ស.ម ជម្រៅ ០១-០៣ ម | ខែ ១ - ខែ ៦ |
| សន្ទូច | ផ្លែ | ១១គ្រួសារ x ១០០ផ្លែ =១.១០០ផ្លែ | ផ្លែលេខ ១២-០៨ | ខែ ៧ - ខែ ១២ |
| លប | គ្រឿង | ៣៦គ្រួសារ x ៤ = ១៤៤ គ្រឿង | មុខកាត់ ០.៥០ម បណ្ដោយ ១.៥០ម | ខែ ០៦ - ខែ ១១ |
| ចាន់ | គ្រឿង | ០២ គ្រួសារ x ៣ =៦គ្រឿង | មុខកាត់ ០.៣០ម បណ្ដោយ០.៦០ម | ខែ ០៦ - ខែ ១១ |

| | | | | |
|---|---|---|---|---|
| សំណាញ់ | វង | ៥៧ គ្រួសារ x ១ = ៥៧វង់ | សំរុង ៣.៥០-៥.៥០ម | នេសាទពេញ១ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំនួនទូក | កំលាំងសេះ |
|---|---|---|---|
| ទូកដឹកទំនិញម៉ាស៊ីនHONDA | ១៥ | ១៥ | ១៣ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ២៤ | ២៤ | ៩ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៥២ | ៥២ | ៦.៥០ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៣ | ៣ | ៥.៥០ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៣៧ | ៣៧ | ៦ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៤ | ៤ | ៧ |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ២ | ២ | ៦.៥ |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ១២ | ១២ | ៧-៧.៥ |
| សរុប | ១៤៩ | ១៦៤ | ៥-១៣ |

ឧបករណ៍នេសាទ និងទូកការណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ឧបករណ៍នេសាទ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ម៉ែត្រ | ៥គ្រួសារ x ១០០ម =១៥០ម | ក្រឡា ២.៥០-១១ស.ម និង ជម្រៅ២.៥០-៣ ម | ខែ ៣ - ខែ ៤ |
| សន្ទូច | ផ្លែ | ៥ គ្រួសារ x ១០០ម = ៥០០ផ្លែ | ផ្លែលេខ១៥-១២ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ២គ្រួសារ x ១ =២វង់ | ក្រឡា២.៥០ស.ម -៧ ស.ម | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំនួនទូក | ចំណុះ (គក្រ) | កំលាំងសេះ |
|---|---|---|---|---|
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៤ | ៤ | ៣០០- ៤០០ | ៧ |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ១ | ១ | ៣០០- ៤០០ | ៧ |
| សរុប | ០៥ | ០៥ | ៣០០-៤០០ | ៧ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង(ខែ១-ខែ៦) | រដូវវស្សា(ខែ៧-ខែ១២) | សរុបប្រចាំឆ្នាំ |
| ត្រី | ១៥០ | ៦០ | ២១០ |
| ក្តាម ខ្យង ខ្ចៅ | ៨ | ២ | ១០ |
| កំពឹស | ១ | ១ | ២ |
| សរុប | ១៥៩ | ៦៣ | ២២២ |

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

ក.ទស្សនៈវិស័យ

សហគមន៍នេសាទភូមិកោះស្នែងមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទកន្លែងអន្លង់អភិរក្សព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាពនិងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋ ខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គោលបំណង

- ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ១- ក្នុងទន្លេមេគង្គ | នេសាទពេញមួយឆ្នាំជាលក្ខណៈគ្រួសារ | មង | ជម្រៅ ៣ ម៉ែត្រក្រឡា ២.៥ ដល់ ១៥ ស.ម | ១០០មក្នុង១គ្រួសារ | |
| | | ចាន់ | មុខកាត់៣០-៨០ស.ម ប្រវែង ១ ម៉ែត្រ | ចំនួន៥ ក្នុង១គ្រួសារ | |
| | | លប | មុខកាត់ ០.៨០ម/ ប្រវែង១.៥០ម | ចំនួន៥ ក្នុង១គ្រួសារ | |
| | | ស្នាង | មុខកាត់ ១ ម | ៣ ក្នុង១គ្រួសារ | |
| | | សំណាញ់ | ជម្រៅ ៣-៥ ម៉ែត្រក្រឡា២ ស.ម ដល់ ១៣ ស.ម | ១ វង់ក្នុង១គ្រួសារ | |
| | | សន្ទូចរនង | គ្រួសារ(លេខ១៧-៩) | ៥០ផ្លែ /១ គ្រួសារ | |
| ២- អូរលិចទឹករដូវវស្សា | ខែ៨ - ខែ១២ | មង | ជម្រៅ ៣ ម៉ែត្រ | ៣០ម/គ្រួសារ | |
| | | សំណាញ់ | ជម្រៅ ៣ ម៉ែត្រ | ១វង់ /គ្រួសារ | |
| | | សន្ទូចរនង | ផ្លែ លេខ ១៧-៩ | ៥០ផ្លែ /១ គ្រួសារ | |
| | | លប | មុខកាត់០.៨០ម ប្រវែង១.៥០ម | ៥គ្រឿង/១ គ្រួសារ | |
| | | ទ្រូ | មុខកាត់ ៣០ ស.ម | ១គ្រឿង/១ គ្រួសារ | |

គ.២ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

គោលបំណង

- កំណត់បានព្រំប្រទល់ច្បាស់លាស់នៃសហគមន៍នេសាទភូមិកោះស្នែង
- សមាជិកនិងប្រជាពលរដ្ឋបានស្គាល់កន្លែងនេសាទសហគមន៍បានច្បាស់លាស់

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍កោះព្រះ ២.៨៨០ ហិកតា | បង្គោលព្រំធ្វើពីស៊ីម៉ងចំនួន ៨បង្គោល | -រៀបចំក្រុមបោះបង្គោល<br>-ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល<br>-ផ្សព្វផ្សាយជាសាធារណ: | -គណ:កម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ២០១៦ | ២០១៦ |
| | ផ្ទាំងប៉ាណូផែនទីស/ហ នេសាទចំនួន៣ផ្ទាំង | ផលិតនិងបោះផ្ទាំងប៉ាណូផែនទី | -គណ:កម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ២០១៦ | ២០១៨ |

គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

គោលបំណង

- បង្កើនពូជត្រីនិងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រក និងប្រភពចំណីរបស់ត្រី និងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឲ្យចេះស្រឡាញ់ថែរក្សាការពារធនធានធម្មជាតិ ជាពិសេសធនធានជលផល និងបរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សតាថាវនៃសហគមន៍នេ | ទំហំ៨,៥ ហិកតា | -ត្រីគ្រប់ប្រភេទ<br>- សត្វទឹកគ្រប់ប្រភេទ | - ផ្សព្វផ្សាយសារ:ប្រយោជន៍កន្លែងអភិរក្ស<br>-កំណត់ព្រំប្រទល់ | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| សាទភូមិ កោះស្នែង | | - ព្រៃលិចទឹក គ្រប់ប្រភេទ។ | កន្លែងអភិរក្ស<br>- បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់<br>-ផលិតនិងផ្សព្វផ្សាយផែនទីកន្លែងអភិរក្ស<br>- ជួសជុលរោងយាម<br>-ចុះល្បាតជាប្រចាំ | | | |

គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

គោលបំណង

- ថែរក្សាការពារព្រៃលិចទឹកឲ្យគង់វង្សយូរអង្វែង
- ទុកជាជម្រកត្រី និងសត្វពងកូនរក្សាលំនឹងបរិស្ថានក្នុងសហគមន៍នេសាទ
- បង្កើនទិន្នផលត្រីដើម្បីលើកកម្ពស់ជីវភាពរស់នៅ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ការថែរក្សាព្រៃលិចទឹកនៅសហគមន៍នេសាទភូមិកោះស្នែង | ៨០ហិកតា | ព្រៃលិចទឹកដែលត្រូវធ្វើការពារនូវប្រភេទ ឈើរាំងត្រស់ ទន្លាឃ្លេរំចេកនិងប្រភេទ ព្រៃចំរុះ | - ផ្សព្វផ្សាយឲ្យបានទូលាយពីសារៈសំខាន់ព្រៃលិចទឹក<br>- ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក<br>- ថែរក្សាចុះល្បាតជាប្រចាំ | ២០១៦ | ២០១៨ | |

គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

គោលបំណង

- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយការចាប់ត្រីក្នុងដែននេសាទ

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ៣០គ្រួសារចិញ្ចឹមត្រីអណ្តែងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១ឆ្នាំ ១០គ្រួសារ) | -ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែង<br>-ធ្វើអាង និងដាក់កូនត្រីចិញ្ចឹម<br>-ត្រួតពិនិត្យតាមដាន | ៣០ អាងទំហំ ២ម x ៤ម | ត្រីអណ្តែង | ១២.០០០ | ២០១៦ | ២០១៨ |

គ.៦ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព

គោលបំណង

- ដើម្បីឲ្យប្រជាពលរដ្ឋមានមុខរបរបង្កើនប្រាក់ចំណូល
- ជួយកាត់បន្ថយអត្រាចំណាក់ស្រុក
- ផ្តល់ចំណេះដឹងជំនាញ និង បច្ចេកទេស (ចិញ្ចឹមត្រី សត្វ កសិកម្មសមស្រប) ។

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ៣០គ្រួសារដាំបន្លែតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលបច្ចេក | គ្រាប់ពូជបន្លែ | គ្រាប់ពូជ ៥ ប្រភេទ/គ្រួសារ | ២០១៦ | ២០១៨ |

| | | | | | |
|---|---|---|---|---|---|
| (១ឆ្នាំ ១០ គ្រួសារ) | ទេសដាំបន្លែជាលក្ខណៈគ្រួសារ<br>- ចែកគ្រាប់ពូជដំណាំអនុវត្តផ្ទាល់<br>- ត្រួតពិនិត្យតាមដាន | | | | |
| ១៥គ្រួសារបណ្តុះផ្សិតអំបោះ និងផ្សិតចំបើងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១ឆ្នាំ ៨គ្រួសារ) | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសដាំផ្សិតអំបោះ និងផ្សិតចំបើងជាលក្ខណៈគ្រួសារ<br>- ចែកមេពូជអនុវត្តផ្ទាល់<br>- ត្រួតពិនិត្យតាមដាន | គ្រាប់ពូជផ្សិត | ៦០០ មេពូជផ្សិត | ២០១៦ | ២០១៧ |
| ៣០ គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១០ គ្រួសារក្នុង ១ ឆ្នាំ) | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ<br>- ផ្តល់ពូជនិងសំភារៈ<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក | ១៨០ក្បាល(៦ក្បាល / ១គ្រួសារ) | ២០១៦ | ២០១៨ |
| ៣៥ គ្រួសាចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១២គ្រួសារ១ឆ្នាំ) | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមជ្រូកតាមបច្ចេក | ពូជក្រៅស្រុក | ៣៥ ក្បាល (១ក្បាល/១ គ្រួសារ) | ២០១៦ | ២០១៨ |

| | | | | | |
|---|---|---|---|---|---|
| | ទេសជាលក្ខណៈ<br>គ្រួសារ<br>-រកទិញពូជនិងសំភារៈ<br>-តាមដានត្រួតពិនិត្យ | | | | |

គ.៧ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

គោលបំណង

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសម្រាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់និងកែច្នៃផលនេសាទចំនួន ១ ក្រុម ៧នាក់ | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ ឬកែច្នៃផលនេសាទដល់គ្រួសារកសិករ<br>- ជ្រើសរើសអ្នកទទួលផល<br>- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន លេខា និងហិរញ្ញឹក<br>- បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>- ផ្តល់ទុន<br>- ត្រួតពិនិត្យតាមដាន | ២០១៧ | ២០១៧ | |
| បង្កើតឡជីវឧស្ម័ន ៥ គ្រួសារ | - ផ្សព្វផ្សាយពីគោលបំណងនៃគម្រោង<br>-សិក្សាប៉ាន់ប្រមាណអ្នកប្រើប្រាស់<br>-បង្កើតគោលការប្រើប្រាស់<br>-បណ្តុះបណ្តាលបច្ចេកទេស | ២០១៧ | ២០១៨ | |

| | | | | |
|---|---|---|---|---|
| | -ទិញសំភារៈអនុវត្តផ្ទាល់<br>-ត្រួតពិនិត្យ និងតាមដាន | | | |
| ៣០<br>គ្រួសារប្រព័ន្ធអគ្គិសនីក្នុងសហគមន៍ពន្លឺព្រះអាទិត្យ<br>(១០គ្រួសារក្នុង១ឆ្នាំ) | - ផ្សព្វផ្សាយពីគោលបំណងនៃគម្រោង<br>-សិក្សាប៉ាន់ប្រមាណអ្នកប្រើប្រាស់<br>- បង្កើតគោលការប្រើប្រាស់<br>- បណ្តុះបណ្តាលបច្ចេកទេស<br>- ទិញសំភារៈ/អនុវត្ត<br>- ត្រួតពិនិត្យ និង តាមដាន | ២០១៧ | ២០១៨ | |
| រៀបចំប្រព័ន្ធទឹកស្អាតចំនួន ៣ កន្លែងជាបណ្តាញ(ធ្វើជាអាងស្តុក និងបណ្តាញចែកចាយ) | - ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់<br>- សិក្សាប៉ាន់ប្រមាណអ្នកប្រើប្រាស់<br>- បណ្តុះបណ្តាលពីរបៀបប្រើប្រាស់និងថែទាំ<br>-ត្រួតពិនិត្យទីតាំងកន្លែងធ្វើអាងស្តុកទឹកដើម្បីចែកចាយ<br>- អនុវត្តសកម្មភាព<br>- ត្រួតពិនិត្យនិងតាមដាន | ២០១៧ | ២០១៨ | |

គ.៨ ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

គោលបំណង

- គណៈកម្មការសហគមន៍នេសាទមានភាពសកម្មការងារ
- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/ខែ | ២០១៦ | ២០១៨ |
| ចូលរួមប្រជុំប្រចាំខែជាមួយឃុំ | ១ដង/ខែ | ២០១៦ | ២០១៨ |
| បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងការរក្សាទុកឯកសារ | ១លើក | ២០១៦ | ២០១៨ |
| បណ្តុះបណ្តាលសរសេរគម្រោងសំណើរ | ១លើក | ២០១៧ | ២០១៧ |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០១៧ | ២០១៧ |
| បណ្តុះបណ្តាលស្តីពីលិខិតបទដ្ឋានគតិយុទ្ធ | ១លើក | ២០១៧ | ២០១៧ |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្ត/ក្រៅប្រទេស | ១លើក | ២០១៧ | ២០១៧ |
| បណ្តុះបណ្តាលពីជំនាញដោះស្រាយទំនាស់ | ១លើក | ២០១៨ | ២០១៨ |
| បណ្តុះបណ្តាលពីជំនាញសម្របសម្រួល | ១លើក | ២០១៨ | ២០១៨ |

គ.៩ ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

គោលបំណង

- ដើម្បីបង្កើនសមត្ថភាពគណៈកម្មការនិងសមាជិកសហគមន៍នេសាទ
- សមាជិកសហគមន៍មានចំណេះដឹងដែលអាចផ្សព្វផ្សាយបន្តទៅសមាជិកផ្សេង
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

| ផែនការ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | ១ដង/ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយច្បាប់ជលផល/បរិស្ថាន/អនុក្រឹត | ១ដង/ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ២០១៦ | ២០១៨ |

គ.១០ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

គោលបំណង

-ដើម្បីឲ្យគណៈកម្មការ និងសមាជិកសហគមន៍នេសាទអនុវត្តផែនការបានជោគជ័យ

-មានផែនការយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការស្វែងរកប្រាក់ចំណូល

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | ២០១៦ | ២០១៨ | ៣៨ | ១៥២នាក់ |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០១៦ | ២០១៨ | ១០៨ | ១៨៩ គ្រួសារ |
| ភាគទានអ្នកនេសាទខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ ប្រមូលប្រាក់ភាគទានពី | ២០១៦ | ២០១៨ | ៥.៤០០ | ៣០ទូក *x* ២ថ្ងៃ/ខែ |
| | អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | | | ៦៨៤ | ៧៦ ទូក *x* ១ថ្ងៃ/ខែ |
| បដិភាគរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ឃុំ | បញ្ចូលផែនការអភិវឌ្ឍសហគមទៅ និងផែនការអភិវឌ្ឍន៍ឃុំ ស្នើសុំប្រាក់បដិភាគពីឃុំដើម្បីអនុវត្តផែនការ | ២០១៦ | ២០១៨ | ៥៨.៣១១ | |

ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឲ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមានៈសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ការពាថែរក្សាព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនង ជាមួយស្ថាប័នជំនាញអង្គការនានា គម្រោងនិងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភ គាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិកោះស្នែងរយៈពេល ៣ ឆ្នាំ (២០១៦-២០១៨)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបណ៍នេសាទ | - កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទសហគមន៍<br>- កាត់បន្ថយបាននូវការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ក្នុងកន្លែងនេសាទសហគមន៍<br>- ធនធានជលផលនឹងកើនឡើងមានការចូលរួមគាំទ្រសហគមន៍<br>-សមាជិកសហគមន៍នឹងចូលរួមអនុវត្តតាមប្រកាសពីការប្រើប្រាស់ឧបករណ៍នេសាទលក្ខណ:គ្រួសារ | ១.១៣៥ | -គណ:កម្មការ<br>-សមាជិកស.ន | ២០១៦ | ២០១៨ | |
| ១.១ ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណ: គ្រួសារក្នុង១ឆ្នាំ/២ដង | -អ្នកចូលរួមចំនួន ៨០នាក់(ស្រី ២៥នាក់)ជាសមាជិកសហគមន៍<br>-យ៉ាងតិច ៣០ នាក់ក្នុង ចំណោយ ៨០ នាក់មានសមត្ថភាពផ្សព្វផ្សាយបន្ត | ៨០០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ១.២ កំណត់ប្រភេឧបករណ៍នេសាទ ទំហំចំនួនអ្នកនេសាទប្រចាំថ្ងៃ | សមាជិកសហគមន៍នេសាទប្រមាណ ៦០%នៃសមាជិកសហគមន៍នេសាទចូលរួមអនុវត្តតាមបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទស្តីពីការប្រើប្រាស់ឧបករណ៍នេសាទ | ១៥ | | ២០១៦ | ២០១៨ | |
| ១.៣ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ពន្ធ អជ្ញាធរដែនដីនិងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ដ៏ទៃ | ៨០ | | ២០១៦ | ២០១៨ | |
| ១.៤ត្រួតពិនិត្យនិងតាមដាន | គណ:កម្មការ និងសមាជិកសហគមន៍នេសាទចូលរួមឃ្លាំមើលរាល់សកម្មភាពអ្នកនេសាទ និងរាយការណ៍ | ១៨០ | | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២. ផែនការបោះបង្គោលព្រំប្រទល់/ ផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ភូមិកោះស្មែង | - បង្គោលចំនួន ៨ ដើម នឹងត្រូវបានគេបោះជាព្រំប្រទល់សហគមន៍នេសាទដោយមានការចូលរួមពីសមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញ អ្នកពាក់ព័ន្ធ<br>-ផ្ទាំងប៉ាណូផែនទីចំនួន៣ នឹងត្រូវបានបោះក្នុងសហគមន៍<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់កន្លែងនេសាទសហគមន៍<br>-អ្នកខាងក្រៅសហគមន៍ទទួលស្គាល់ដែននេសាទសហគមន៍ច្បាស់លាស់និងងាយស្រួលក្នុងការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ១.៧២៦ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ២.១ រៀបចំក្រុមទទួលខុសត្រូវនិងចាត់ចែងរកមធ្យោបាយបោះបង្គោល /ផ្ទាំងផែនទីសហគមន៍ នេសាទ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទចូលរួមសកម្មភាពបោះបង្គោលព្រំប្រទល់ | ៥០ | | ២០១៦ | ២០១៦ | |
| ២.២ យុទ្ធនាការបោះបង្គោល និងធ្វើផ្ទាំងប៉ាណូផ្សព្វផ្សាយចំនួន២ផ្ទាំង | បង្គោលចំនួន ៨ ដើមត្រូវបានបោះតាមកន្លែងដែលបានគ្រោងទុកក្នុងដែនសហគមន៍នេសាទដោយមានកសារចូលរួមពីសមាជិកគណៈកម្មការសហគមន៍<br>អាជ្ញាធរមូលដ្ឋានស្ថាប័នជំនាញអ្នកពាក់ព័ន្ធ | ១.៥៧៦ | | ២០១៦ | ២០១៦ | |
| ២.៣ ផ្សព្វផ្សាយជាសាធារណៈ | អ្នកចូលរួមចំនួន ៨០នាក់ស្រី ២៥នាក់សមាជិកសហគមន៍នេសាទ | ១០០ | | ២០១៦ | ២០១៨ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់តាថាវ | -រក្សាបាននៅប្រភេទត្រីមេពូជ<br>-ត្រីនិងសត្វគ្រប់ប្រភេទនឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍គ្រប់គ្រង | ៥.៩៧០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣.១ ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស | -ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងចូលរួមថែរក្សា<br>-សហគមន៍មានកន្លែងអភិរក្សច្បាស់លាស់ | | -សប្បុរសជន | ២០១៦ | ២០១៨ | |
| ៣.២ បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់ | -ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន២ត្រូវបានដាក់សំគាល់<br>-ទង់សំគាល់កន្លែងអភិរក្សចំនួន ៣០ទង់ | ៦៩០ | | ២០១៦ | ២០១៨ | |
| ៣.៣ ផលិតនិងផ្សព្វផ្សាយផែនទីកន្លែងអភិរក្ស | -សមាជិកសហគមន៍នេសាទចំនួន ៣៥នាក់ស្រី១៥នាក់ចូលរួមនិងយល់ដឹងពីកន្លែងអភិរក្ស<br>-ផែនទីចំនួន១ផ្ទាំងត្រូវបានដាក់នៅកន្លែងអភិរក្ស | ៦០០ | | ២០១៦ | ២០១៨ | |
| ៣.៤ ជួសជុលរោងយាម | រោងយាមចំនួន០១ត្រូវបានជួសជុលនៅកន្លែងអភិរក្សទំហំ ៤x៥ | ៣.០០ | | ២០១៦ | ២០១៨ | |
| ៣.៥ ទិញសម្ភារៈចុះល្បាតជាប្រចាំ | | ៤.៣៨០ | | ២០១៦ | ២០១៨ | |
| ៤<br>ផែនការគ្រប់គ្រងព្រៃលិចទឹកគោលដៅសហគមន៍នេសាទភូមិកោះស្នែង | | ១.៦២០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ | ២០១៦ | ២០១៨ | |
| ៤.១ ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹកដល់សមាជិកសហគមន៍នេសាទ | -សមាជិកសហគមន៍នេសាទចំនួន ៣០នាក់ស្រី ១៥នាក់ចូលរួមកិច្ចប្រជុំ<br>-សហគមន៍ចូលរួមក្នុងការការពារថែរក្សាព្រៃលិចទឹក | ៣០០ | -សប្បុរសជន | ២០១៦ | ២០១៨ | |
| ៤.២ ដាក់ស្លាក់ហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសំគាល់ | -សមាជិកសហគមន៍នេសាទយល់ដឹងពីសារៈប្រយោជន៍ព្រៃលិចទឹកចូលរួមថែរក្សា<br>-ស្លាកសញ្ញាហាមកាមព្រៃលិចទឹកចំនួន ៣០០ស្លាកត្រូវបានដាក់តាមដើមឈើ | ៦០០ | | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤.៣ ចុះល្បាតជាប្រចាំ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទចូលរួមយ៉ាងសកម្មក្នុងការពារ ទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក | ៧២០ | | ២០១៦ | ២០១៨ | |
| ៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | |
| ៥.១ ៣០គ្រួសារចិញ្ចឹមត្រីអណ្តែងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - សមាជិកសហគមន៍នេសាទចំនួន ៣០ គ្រួសារចិញ្ចឹម ត្រីអណ្តែងអាងចំនួន ១២,០០០ក្បាល<br>- សមាជិកសហគមន៍នេសាទប្រមាណ ៦០% នឹងមាន ចំណេះដឹងលើការចិញ្ចឹមត្រីអណ្តែងតាមលក្ខណៈបច្ចេកទេសក្នុងគ្រួសារ<br>- នឹងជួយកាត់បន្ថយបានការនេសាទត្រីពីធម្មជាតិ<br>- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍ | ១២.៩៦០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | | | |
| ៥.១.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | | ៣៦០ | | ២០១៦ | ២០១៨ | |
| ៥.១.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែង | | ៣០០ | | ២០១៦ | ២០១៨ | |
| ៥.១.៣ ធ្វើអាង និងទិញកូនត្រីដាក់ក្នុងអាង | | ១០.៥០០ | | ២០១៦ | ២០១៨ | |
| ៥.១.៤ ត្រួតពិនិត្យតាមដាន | | ១៨០ | | ២០១៦ | ២០១៨ | |
| ៦ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | | ៦.៤៤០ | | | | |
| ៦.១. ៣០ គ្រួសារ ដាំបន្លែជាលក្ខណៈដល់គ្រួសារកសិករ | - គ្រួសារកសិករចំនួន ៣០ គ្រួសារទទួលគ្រាប់ពូជបន្លែ គ្រប់ប្រភេទ<br>- គ្រួសារកសិករប្រមាណ ៣០គ្រួសារ នឹងមានចំណេះដឹង លើបច្ចេកទេសសួនបន្លែជាលក្ខណៈគ្រួសារកសិករ<br>- បង្កើនមុខរបរ និងប្រាក់ចំណូលដល់គ្រួសារកសិករ | ៩៩៥ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.១.១ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | | ១៥០ | | ២០១៦ | ២០១៨ | |
| ៦.១.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើសួនបន្លែជាគ្រួសារ | | ៣០០ | | ២០១៦ | ២០១៨ | |
| ៦.១.៣ ចែកគ្រាប់ពូជ អនុវត្តផ្ទាល់ | | ៤៥០ | | ២០១៦ | ២០១៨ | |
| ៦.១.៤ ត្រួតពិនិត្យតាមដាន | | ៩៥ | | ២០១៦ | ២០១៨ | |
| ៦.២. ១៥ គ្រួសារបណ្តុះផ្សិតអំបោះ និងផ្សិតចំបើងជាលក្ខណៈគ្រួសារ | - គ្រួសារកសិករចំនួន ១៥ គ្រួសារទទួលបានពូជផ្សិតអំបោះ និងផ្សិតចំបើង | ១.០២០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦.២.១ ជ្រើសរើសគ្រួសារកសិករស្មគ្រ័ចិត្ត | - គ្រួសារកសិករប្រមាណ ១៥គ្រួសារ នឹងមានចំណេះដឹងលើបច្ចេកបណ្តុះផ្សិតជាលក្ខណៈគ្រួសារកសិករ<br>- បង្កើនមុខរបរ និងប្រាក់ចំណូលដល់គ្រួសារកសិករ | ១០០ | -អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.២.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើបណ្តុះផ្សិតចំបើង និងផ្សិតអំបោះជាគ្រួសារ | | ២០០ | | ២០១៦ | ២០១៨ | |
| ៦.២.៣ ចែកពូជ អនុវត្តផ្ទាល់ | | ៦០០ | | ២០១៦ | ២០១៨ | |
| ៦.២.៤ ត្រួតពិនិត្យតាមដាន | | ១២០ | | ២០១៦ | ២០១៨ | |
| ៦.៣ ៣០ គ្រួសារបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ | - សមាជិកសហគមន៍នេសាទចំនួន ៣០ គ្រួសារទទួលបានមាន់ចំនួន ១៨០មេ និងឈ្មោលមាន់សំរាប់ធ្វើពូជ<br>- បង្កើនមុខរបរដល់សមាជិកសហគមន៍នេសាទ<br>- សមាជិកសហគមន៍នេសាទប្រមាណ ៦០%មានយល់នៃចំនួនកសិករដឹងលើបច្ចេកទេសចិញ្ចឹមមាន់តាមលក្ខណៈគ្រួសារ<br>- បង្កើនប្រាក់ចំណូលដល់សហគមន៍នេសាទ | ៩៩៥ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.៣.១ ជ្រើសរើសអ្នកទទួលផល | | ១៥០ | | ២០១៦ | ២០១៨ | |
| ៦.៣.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ | | ៣០០ | | ២០១៦ | ២០១៨ | |
| ៦.៣.៣ ផ្តល់ពូជ និងទិញសំភារៈ | | ៤៥០ | | ២០១៦ | ២០១៨ | |
| ៦.៣.៤ត្រួតពិនិត្យនិងតាមដាន | | ៩៥ | | ២០១៦ | ២០១៨ | |
| ៦.៤ ៣៥ គ្រួសារបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ | - សមាជិកសហគមន៍នេសាទចំនួន ៣៥ គ្រួសារទទួលបានជ្រូកចំនួន ៣៥មេ សំរាប់ធ្វើពូជ<br>- បង្កើនមុខរបរដល់សមាជិកសហគមន៍នេសាទ<br>- សមាជិកសហគមន៍នេសាទប្រមាណ ៦០%មានយល់នៃចំនួនកសិករដឹងលើបច្ចេកទេសចិញ្ចឹមជ្រូកតាមលក្ខណៈគ្រួសារ<br>- បង្កើនប្រាក់ចំណូលដល់សហគមន៍នេសាទ | ៣.៤៣០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.៤.១ ជ្រើសរើសអ្នកទទួលផល | | ១៥០ | | ២០១៦ | ២០១៨ | |
| ៦.៤.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ | | ៣០០ | | ២០១៦ | ២០១៨ | |
| ៦.៤.៣ ផ្តល់ពូជ និង ទិញសំភារៈ | | ២.៨០០ | | ២០១៦ | ២០១៨ | |
| ៦.៤.៤ត្រួតពិនិត្យនិងតាមដាន | | ១៨០ | | ២០១៦ | ២០១៨ | |
| ៧.ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ | | ២៧.៥៩០ | | | | |
| ៧.១. បង្កើតក្រុមសន្សំប្រាក់ | សមាជិកសហគមន៍នេសាទចំនួន ៤៥ គ្រួសារ | ១.៧០០ | -សហគមន៍ស.ន | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
